យើងរស់នៅក្នុងពិភពលោកនេះ ក្នុងរូបកាយសាច់ឈាម និងក្នុងពិភពដែលស្ថិតនៅក្រោមពេលវេលា។ ប៉ុន្តែ សង្គ្រាមរបស់យើងមិនមែនស្ថិតនៅក្នុងអាណាចក្រនោះទេ។ សង្គ្រាមរបស់យើងស្ថិតនៅក្នុងអាណាចក្រខាងវិញ្ញាណ។ ដូច្នេះ អាវុធដែលព្រះបានប្រទានឲ្យយើង ក៏សមស្របនឹងអាណាចក្រដែលយើងត្រូវប្រយុទ្ធផងដែរ។ យើងមិនអាចទទួលជ័យជម្នះដោយកាំភ្លើង រថក្រោះ ឬមីស៊ីលបានទេ ពីព្រោះអាវុធទាំងនោះមិនអាចទៅដល់សត្រូវដែលយើងកំពុងប្រឈមមុខបានឡើយ។

មេគ្រប់គ្រងនៅសម័យបច្ចុប្បន្ននេះ មានការរាំងស្ទះដោយសារតែពួកគេ មិនមានវិធីសាស្ត្រដើម្បីចូលទៅដល់កន្លែងដែលលទ្ធផលបានកំណត់ពិតប្រាកដ។ ប៉ុន្តែ អ្នក និងខ្ញុំ មានមធ្យោបាយនោះ។ អាវុធនៃសង្គ្រាមរបស់យើងមិនមែនជាអាវុធខាងសាច់ឈាមទេ ប៉ុន្តែមានឫទ្ធានុភាពដោយព្រះ សម្រាប់រំលំទីរឹងមាំរបស់សាតាំងនៅក្នុងអាណាចក្រដែលមើលមិនឃើញ។

សូមកត់សម្គាល់ពាក្យនៅក្នុងគម្ពីរ ២កូរិនថូស 10:5 ដែលបង្ហាញថា អាវុធរបស់យើងមានឥទ្ធិពលលើមនុស្សជាតិយ៉ាងដូចម្តេច៖ *"ដែលអាចនឹងរំលាយអស់ទាំងគំនិតដែលគេរិះគិត នឹងគ្រប់ទាំងសេចក្តីយ៉ាងខ្ពង់ខ្ពស់ ដែលលើកខ្លួនឡើងទាស់នឹងចំណេះនៃព្រះ ព្រមទាំងនាំអស់ទាំងគំនិត ឲ្យចុះចូលស្តាប់បង្គាប់ព្រះគ្រីស្ទវិញ ។"* បន្ទាយ រឹងមាំ ការវែកញែក ចំណេះ និងគំនិតទាំងឡាយ សុទ្ធតែស្ថិតនៅក្នុងអាណាចក្រដែលមើលមិនឃើញ។ អាណាចក្រនោះហើយដែលគ្រប់គ្រងការគិត ការវែកញែក និងការយល់ដឹងរបស់មនុស្ស។ សង្គ្រាមរបស់ពួកជំនុំកើតឡើងនៅក្នុងអាណាចក្រនោះ ហើយព្រះបានប្រទានអាវុធខាងវិញ្ញាណដល់យើង ដែលអាចធានាបាននូវជ័យជម្នះខាងវិញ្ញាណ ប្រសិនបើយើងប្រើប្រាស់អាវុធទាំងនោះ។

ការស្ម័គ្រចិត្តបម្រើ

ប្រហែលជាអ្នកកំពុងសួរខ្លួនឯងថា "តើខ្ញុំប្រើអាវុធខាងវិញ្ញាណទាំងនេះយ៉ាងដូចម្តេច?" ខ្ញុំជឿថា វាសមស្របណាស់ក្នុងការអញ្ជើញអ្នកឲ្យអធិស្ឋានអំពីប្រធានបទជាក់លាក់មួយ គឺសូមឲ្យព្រះបំពាក់បំប៉ន និងប្រទានសមត្ថភាពដល់អ្នក ដើម្បីបំពេញតួនាទីដែលទ្រង់រំពឹងឲ្យអ្នកបំពេញនៅក្នុងពិភពលោកនេះ។

ប្រហែលជាអ្នកមានអារម្មណ៍ថា រហូតមកដល់ពេលនេះ អ្នកមិនទាន់បានបំពេញតួនាទីនោះយ៉ាងពិតប្រាកដនៅឡើយទេ។ ប្រហែលជាអ្នកមិនធ្លាប់ដឹងផងថា ព្រះបានត្រាស់ហៅអ្នកឲ្យចូលរួមក្នុងសង្គ្រាមខាងវិញ្ញាណ។ ប៉ុន្តែឥឡូវនេះ ដោយបានឃើញពីព្រះបន្ទូលរបស់ទ្រង់ថា អ្នកត្រូវបានត្រាស់ហៅ អ្នកបានក្លាយជាអ្នកស្ម័គ្រចិត្តដោយចិត្តស្មោះ។

ប្រសិនបើនោះជាករណីរបស់អ្នក ខ្ញុំសូមណែនាំឲ្យអ្នក ខ្ញុំសូមណែនាំឲ្យអ្នកចូលទៅកាន់អាសនៈរបស់ព្រះ នៅក្នុងពេលវេលាដ៏សំខាន់នេះ ហើយគ្រាន់តែប្រាប់ទ្រង់អំពីឆន្ទៈរបស់អ្នក។ ចូរថ្វាយខ្លួនអ្នកដល់ព្រះ ជាអ្នកស្ម័គ្រចិត្តសម្រាប់ការប្រយុទ្ធខាងវិញ្ញាណ ជាពិសេសសម្រាប់ការប្រយុទ្ធខាងវិញ្ញាណ ដែលនឹងមានឥទ្ធិពលលើជោគវាសនារបស់ប្រទេសជាតិរបស់អ្នក។

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ! ទូលបង្គំសូមថ្វាយខ្លួនដល់ទ្រង់ ជាអ្នកស្ម័គ្រចិត្តសម្រាប់ការប្រយុទ្ធខាងវិញ្ញាណ ដែលទ្រង់បានត្រាស់ហៅទូលបង្គំឲ្យចូលរួម។ ទូលបង្គំទូលសូមឲ្យទ្រង់ ប្រើទូលបង្គំជាពិសេស ក្នុងការប្រយុទ្ធក្នុងសង្គ្រាមខាងវិញ្ញាណ ដែលកំពុងត្រូវប្រយុទ្ធសម្រាប់ប្រជាតិជាតិរបស់ទូលបង្គំ នៅក្នុងអាណាចក្រស្ថានសួគ៌នៅពេលនេះ។

សូមប្រើទូលបង្គំ ដូចជា ហោរាដានីយ៉ែល ដើម្បីបំពេញគោលបំណងរបស់ទ្រង់នៅលើផែនដី តាមរយៈការអធិស្ឋាន និងសង្គ្រាមខាងវិញ្ញាណ។ សូមបំពាក់បំប៉ន និងប្រទានសមត្ថភាពដល់ទូលបង្គំ ដើម្បីបំពេញតួនាទីដែលទ្រង់បានរៀបចំសម្រាប់ទូលបង្គំក្នុងពិភពលោកនេះ ខណៈដែលទូលបង្គំពឹងផ្អែកទាំងស្រុងលើទ្រង់ និងលើព្រះចេស្តាដ៏មានឫទ្ធានុភាពរបស់ទ្រង់។ ទូលបង្គំអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន!

ស្វែងយល់ពីព្រះបន្ទូលព្រះឲ្យកាន់តែស៊ីជម្រៅ

សម្រាប់ការបង្រៀនបន្ថែមអំពីប្រធានបទនេះ សូមចូលទៅកាន់គេហទំព័ររបស់យើង៖
www.derekprince.com/km-kh/resources

ស្កេន QR ដើម្បីចូលគេហទំព័រ DPM-KH

ព័ន្ធកិច្ច ដេរេក ព្រីនស៍ កម្ពុជា
Facebook / Youtube: Derek Prince Ministries Cambodia | www.derekprince.com/km-kh

ISSUE #097
លោកដេរេក ព្រីនស៍៖ សេចក្តីបង្រៀនជាលិខិត
ការយល់ដឹងពីព្រះគម្ពីរ ដើម្បីផ្លាស់ប្រែជីវិតរបស់អ្នក
Free COPY



ការរស់នៅជាអំបិល និងពន្លឺ

ផ្នែកទី ៣៖ការតយុទ្ធសម្រាប់ប្រជាជាតិរបស់យើង

នៅក្នុងស៊េរីកេរដំណែលនៃសេចក្តីបង្រៀនចំនួនបីផ្នែកនេះ ដែលផ្អែកលើសៀវភៅដ៏ល្បីល្បាញរបស់លោក ដេរេក ព្រីនស៍ ដែលមានចំណងជើងថា ការរស់នៅជាអំបិល និងពន្លឺ យើងបានយល់អំពីតួនាទី ឯកសិទ្ធិ និងការទទួលខុសត្រូវ ដែលព្រះបានប្រទានដល់យើងជាគ្រីស្ទបរិស័ទ ដើម្បីមានឥទ្ធិពលលើប្រទេសដែលយើងរស់នៅ។ នៅក្នុងសៀវភៅរបស់គាត់ លោកដេរេក ព្រីនស៍ បានធ្វើសេចក្តីថ្លែងការណ៍ដ៏មានអំណាចមួយថា៖

"ក្នុងចំណោមស្ថាប័នទាំងអស់នៅលើផែនដីសព្វថ្ងៃនេះ មានតែពួកជំនុំប៉ុណ្ណោះ ដែលមានសមត្ថភាពផ្លាស់ប្តូរស្ថានភាពពិភពលោកឲ្យប្រសើរឡើងយ៉ាងមានប្រសិទ្ធភាព" ។ នៅក្នុងសំបុត្រទីបី និងជាសំបុត្រចុងក្រោយនេះ ដែលមានចំណងជើងថា "ការតយុទ្ធសម្រាប់ប្រជាជាតិរបស់យើង" លោក ដេរេក បានពិនិត្យអំពីគោលការណ៍ដ៏សំខាន់មួយ គឺ សង្គ្រាមខាងវិញ្ញាណ ដែលយើងជួបប្រទះនៅពេលយើងអធិស្ឋានទូលអង្វរសម្រាប់ប្រជាជាតិរបស់យើងនីមួយៗ។ ការយល់ដឹងអំពីសេចក្តីពិតនេះ នឹងជួយឲ្យយើងបំពេញការទទួលខុសត្រូវរបស់យើង ក្នុងការធ្វើជាអំបិល និងជាពន្លឺនៅក្នុងប្រទេសដែលព្រះបានត្រាស់ហៅយើងឲ្យរស់នៅ។

ការមកជួបរបស់ទេវតា

គោលការណ៍នេះអាចរកឃើញនៅក្នុងរឿងដែលហោរដានីយ៉ែល បានជួបប្រទះ ក្នុងការប្រឈមមុខនឹងការតស៊ូខាងវិញ្ញាណ។ ដំណើររឿងនេះ ចាប់ផ្តើមដោយសេចក្តីថ្លែងការណ៍ដ៏សាមញ្ញមួយរបស់ដានីយ៉ែលថា៖ *"នៅគ្រានោះ ខ្ញុំដានីយ៉ែល ខ្ញុំមានសេចក្តីទុក្ខព្រួយនៅពេញ៣អាទិត្យ"* ដានីយ៉ែល 10:2 ។ លោកដានីយ៉ែល បានតាំងចិត្តដើម្បីអធិស្ឋាន និងការតមអាហារជាពិសេសរយៈពេល៣សប្តាហ៍ ដើម្បីស្វែងរកព្រះឲ្យកាន់តែមានប្រសិទ្ធភាព។ នៅចុងបញ្ចប់នៃរយៈពេលបីសប្តាហ៍នោះ ចម្លើយចំពោះការអធិស្ឋានរបស់ដានីយ៉ែលបានមកដល់ តាមរយៈការចុះមកជួបរបស់មហាទេវតាកាព្រីយ៉ែល។

រួចលោក (កាព្រីយ៉ែល) ប្រាប់ខ្ញុំថា ដានីយ៉ែលអើយ កុំឲ្យខ្លាចឡើយ ដ្បិតចាប់តាំងពីថ្ងៃមុនដំបូង ដែលអ្នកបានតាំងចិត្តរកយល់ ហើយបន្ទាបខ្លួនចុះ នៅចំពោះព្រះនៃអ្នក នោះពាក្យរបស់អ្នកក៏បានឮហើយ រួចយើងក៏បានមក ដោយព្រោះពាក្យនោះ។
(ដានីយ៉ែល 10:12)

ការអធិស្ឋានរបស់ដានីយ៉ែលត្រូវបានឮតាំងពីថ្ងៃដំបូង ប៉ុន្តែចម្លើយបានមកដល់នៅថ្ងៃទីម្ភៃមួយ។ ហេតុអ្វីបានជាគាត់ត្រូវរង់ចាំរយៈពេលបីសប្តាហ៍? នេះគឺជាហេតុផលដែលកាព្រីយ៉ែលបានប្រាប់ថា៖

ប៉ុន្តែ ម្ចាស់ដ៏ធំនៃនគរពើស៊ី បានឃាត់យើងអស់២១ថ្ងៃ តែមើល មីកែល ជាពួកមហាទេវតា១បានមកជួយ យើងយ៉ាងនោះ យើងបាននៅទីនោះជាមួយនឹងពួកស្តេចពើស៊ីទៅ។

(ដានីយ៉ែល 10:13)

សូមចំណាំថា «ម្ចាស់ដ៏ធំនៃនគរពើស៊ី» មិនមែនជាមនុស្សទេ ប៉ុន្តែ ជាអំណាចនៃវិញ្ញាណដែលគ្រប់គ្រងពីក្រោយនគរពើស៊ីនៅលើផែនដី។ នៅពេលដែលដានីយ៉ែលចាប់ផ្តើមអធិស្ឋានសម្រាប់ការស្តារអ៊ីស្រាអែល ឲ្យរួចផុតពីការជាប់ជាឈ្លើយ (ដែលមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងអាណាចក្រពើស៊ី) ព្រះបានឆ្លើយតបភ្លាមៗ ដោយចាត់ទេវតា កាព្រីយ៉ែល ឲ្យនាំចម្លើយមកកាន់ដានីយ៉ែល។ ប៉ុន្តែ អំណាចអាក្រក់ដែលមើលមិនឃើញនេះ បានប្រឆាំងនឹងកាព្រីយ៉ែលនៅក្នុងអាណាចក្រខាងវិញ្ញាណអស់រយៈពេលម្ភៃមួយថ្ងៃ។

ការចាប់ផ្តើមស្ថិតនៅលើយើង

តើអ្នកកំពុងចាប់ផ្តើមយល់ហើយឬនៅ ថាហេតុអ្វីបានជាពេលខ្លះចម្លើយចំពោះការអធិស្ឋានរបស់អ្នកហាក់ដូចជាយឺតយ៉ាវ? តើអ្នកអាចឃើញទេថា ដូចជាដានីយ៉ែលដែរ អ្នកក៏កំពុងជាប់ពាក់ព័ន្ធក្នុងសង្គ្រាមខាងវិញ្ញាណមួយ? រឿងរ៉ាវខាងលើបង្ហាញនូវការពិតដ៏សំខាន់បំផុតមួយ គឺថាការអធិស្ឋានរបស់ដានីយ៉ែលនៅលើផែនដី បានជំរុញឲ្យពួកទេវតាធ្វើសកម្មភាពនៅស្ថានសួគ៌។

បងប្អូនអើយ ការចាប់ផ្តើមគឺស្ថិតនៅលើពួកជំនុំ មិនមែននៅលើពួកទេវតាទេ។ លទ្ធផលអាស្រ័យលើអ្វីដែលយើងធ្វើ។ ពួកទេវតាគឺជា *"វិញ្ញាណបំរើ ដែលទ្រង់បានចាត់មកសំរាប់ការងារជួយ ដល់ពួកដែលត្រូវទទួលសេចក្ដីសង្គ្រោះជាមរដក"* (ហេព្រើរ 1:14)។ យើងមិនមែនកំពុងរង់ចាំពួកទេវតាទេ តែពួកទេវតាវិញទេដែលកំពុងរង់ចាំយើង។

នៅពេលអ្នកចាប់ផ្តើមអធិស្ឋាន អ្នកកំពុងជំរុញឲ្យពួកទេវតាធ្វើសកម្មភាព មិនត្រឹមតែពួកទេវតាល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពួកវិញ្ញាណអាក្រក់ផងដែរ ដែលការគ្រប់គ្រងរបស់ពួកវាកំពុងត្រូវបានរំខានដោយការអធិស្ឋានរបស់អ្នក។ ប្រហែលជាអ្នកបានចាប់ផ្តើមស្វែងយល់ហើយថា ការនេះពិតប្រាកដយ៉ាងណា! សូមកត់សម្គាល់ថា គឺការអធិស្ឋានរបស់ដានីយ៉ែល ដែលបានបើកផ្លូវឲ្យទេវតាកាព្រីយ៉ែល អាចមកដល់បាន។

តើអ្នកយល់ទេថា យើងត្រូវធ្វើអ្វី?

នៅក្នុងទំនាក់ទំនងនឹងសង្គ្រាមខាងវិញ្ញាណ យើងគឺជាអ្នកដែលមានការចាប់ផ្តើម។ ពិភពលោកកំពុងរង់ចាំយើង ទាំងពិភពដែលមើលមិនឃើញ និងពិភពដែលមើលឃើញ។ យើងគឺជាមនុស្សដែលនៅទីបំផុត មានឥទ្ធិពលលើជោគវាសនារបស់ប្រជាជាតិទាំងឡាយ។ យើងគឺជាអំបិលនៃផែនដី ហើយយើងគឺជាពន្លឺនៃលោកិយ។

ព្រះគ្រីស្ទធ្វើការតាមរយៈរូបកាយរបស់ទ្រង់

មានហេតុផលសំខាន់មួយទៀត ដែលយើងជាអំបិលនៃផែនដី និងជាពន្លឺនៃលោកិយ។ ដូចដែលព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ យើងគឺជារូបកាយរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល ឧទាហរណ៍៖ អេភេសូ 1:22–23) ហើយព្រះយេស៊ូវគ្រីស្ទ ធ្វើការតាមរយៈរូបកាយរបស់ទ្រង់។ ព្រះជាម្ចាស់នឹងមិនដាក់ព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ឲ្យនៅមួយឡែកទេ ពីព្រោះការធ្វើដូច្នោះគឺជាការមិនលើកតម្កើងដល់ទ្រង់។ ដូចគ្នានេះដែរ ព្រះក៏នឹងមិនដាក់ពួកជំនុំឲ្យនៅមួយឡែកដែរ ពីព្រោះពួកជំនុំគឺជារូបកាយរបស់ព្រះរាជបុត្រាទ្រង់។ នៅក្នុងអធិបតេយ្យភាពរបស់ទ្រង់ ព្រះបានកំណត់ព្រះអង្គទ្រង់ឲ្យធ្វើកិច្ចការសំខាន់ៗ ដែលត្រូវតែធ្វើតាមរយៈពួកជំនុំ។ ហើយ "ពួកជំនុំ" នោះ មានន័យថា លោកអ្នក និងខ្ញុំ។

ខ្ញុំសង្ឃឹមថា អ្នកកំពុងចាប់ផ្តើមយល់ពីសេចក្តីពិតនេះហើយ៖ **អ្នកមានសារៈសំខាន់**។ ខ្ញុំតែងតែមានអារម្មណ៍សោកស្តាយ នៅពេលឮគ្រីស្ទបរិស័ទនិយាយអំពីខ្លួនឯងដូចជាមនុស្សដែលគ្មានសារៈសំខាន់ ឬគ្មានតម្លៃ។ តាមពិតទៅមានរឿងជាច្រើនដែលអាស្រ័យលើអ្នក។ ប្រទេសជាតិរបស់អ្នកអាស្រ័យលើអ្នក។ មេដឹកនាំនយោបាយរបស់អ្នកអាស្រ័យលើអ្នក។ សូម្បីតែទិសដៅនៃប្រវត្តិសាស្ត្រក៏អាស្រ័យលើអ្នកដែរ។ ដល់ពេលដែលអ្នកត្រូវយល់អំពីការនេះហើយ។ រូបភាពមួយទៀតអំពីសកម្មភាពនៅក្នុងអាណាចក្រខាងវិញ្ញាណ ត្រូវបានបង្ហាញឲ្យយើងឃើញនៅក្នុង អេសាយ ជំពូក 24។ ខគម្ពីរនេះពិពណ៌នាអំពីការជំនុំជម្រះចុងក្រោយដ៏ធំ និងដ៏អស្ចារ្យ ដែលនឹងបញ្ចប់យុគសម័យនេះ។ វាជាគ្រាមួយដែលផែនដីទាំងមូលនឹងរង្គោះរង្គើ ងាកចុះឡើង ហើយត្រូវបានកក្រើកដូចជាខ្ទមតូចមួយក្នុងពេលមានរញ្ជួយដី។ ការយាងមករបស់ព្រះអម្ចាស់ដោយសិរីល្អ ត្រូវបានពិពណ៌នាថានឹងកើតឡើងនៅចុងបញ្ចប់នៃគ្រានោះ។ គម្ពីរអេសាយ 24:21 ចែងថា៖ *"នៅគ្រានោះ ព្រះយេហូវ៉ាទ្រង់នឹងផ្ចាញ់ផ្ចាលនៅលើមេឃ ចំពោះពួកពលបរិវារនៃស្ថានខ្ពស់ ព្រមទាំងពួកស្តេចនៃលោកីយនៅផែនដីដែរ"* ។ នៅទីនេះយើងឃើញអាណាចក្រពីរម្តងទៀត "ពួកស្តេចនៃលោកីយនៅផែនដី" និង "ពួកពលបរិវារនៃស្ថានខ្ពស់" (នៅក្នុងអាណាចក្រនៃស្ថានសួគ៌) ដែលនឹងត្រូវទទួលការជំនុំជម្រះពីព្រះ។ នេះហើយជារបៀបដែលអ្វីៗដំណើរការ៖ នៅពីក្រោយអ្វីដែលមើលឃើញ មានអ្វីដែលមើលមិនឃើញ។ នៅពីក្រោយអ្វីដែលជាខាងសាច់ឈាមមានអ្វីដែលជាខាងវិញ្ញាណ។ ហើយអ្វីដែលកើតឡើងនៅក្នុងអាណាចក្រខាងវិញ្ញាណ គឺជាអ្វីដែលសម្រេចលទ្ធផលចុងក្រោយ។

នៅពេលអ្នកទទួលបានជ័យជម្នះ នៅក្នុងអាណាចក្រខាងវិញ្ញាណ នោះអ្នកបានទទួលជ័យជម្នះហើយ។ អ្វីៗទាំងអស់ដែលកើតឡើងបន្តទៀតនៅក្នុងពិភពធម្មជាតិ សង្គម ឬប្រវត្តិសាស្ត្រ គ្រាន់តែជាលទ្ធផលនៃអ្វីដែលត្រូវបានសម្រេចរួចហើយ នៅក្នុងអាណាចក្រខាងវិញ្ញាណប៉ុណ្ណោះ។ ហេតុនេះហើយបានជា ពួកជំនុំមានសមត្ថភាពពេញលេញ ក្នុងការផ្លាស់ប្តូរទិសដៅនៃពិភពធម្មជាតិ និងប្រវត្តិសាស្ត្រ។ អ្វីដែលយើងត្រូវការគឺ ទទួលបានជ័យជម្នះនៅក្នុងអាណាចក្រខាងវិញ្ញាណ។

ព្រះបានប្រទានអាវុធខាងវិញ្ញាណដល់យើង

ដើម្បីបញ្ចប់សារនេះ ខ្ញុំសូមនាំការយកចិត្តទុកដាក់របស់អ្នកទៅកាន់បទគម្ពីរមួយទៀត។ ចំណុចមួយដែលខ្ញុំស្រឡាញ់អំពីព្រះគម្ពីរ គឺថា ព្រះគម្ពីរមានភាពសមហេតុផលឥតខ្ចោះ។ ដោយសារយើងកំពុងចូលរួមក្នុងការប្រយុទ្ធខាងវិញ្ញាណ តើយើងត្រូវការអាវុធប្រភេទណា? យើងត្រូវការអាវុធខាងវិញ្ញាណ។ ហើយនោះហើយជាអ្វីដែលព្រះបានប្រទានឲ្យយើង៖

ដ្បិតទោះបើយើងខ្ញុំដើរក្នុងសាច់ឈាមមែន គង់តែមិនតយុទ្ធតាមសាច់ឈាមទេ ព្រោះគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើងខ្ញុំ មិនមែនជារបស់ខាងសាច់ឈាមទេ គឺជាឥទ្ធិឫទ្ធិដែលមកពីព្រះ សំរាប់នឹងរំលំទីមាំមួនវិញ ដែលអាចនឹងរំលាយអស់ទាំងគំនិតដែលគេរិះគិត នឹងគ្រប់ទាំងសេចក្ដីយ៉ាងខ្ពង់ខ្ពស់ ដែលលើកខ្លួនឡើងទាស់នឹងចំណេះនៃព្រះ ព្រមទាំងនាំអស់ទាំងគំនិតឲ្យចុះចូលស្តាប់បង្គាប់ព្រះគ្រីស្ទវិញ។

(២កូរិនថូស 10:3–5)

